## រឿងទី៧៖ នំបុ័ងប្រាំដុំត្រីពីរកន្ទុយ

**ខគម្ពីរ៖ លូកា៩៖១៦**

ព្រះយេស៊ូយកនំបុ័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ទ្រង់ងើបព្រះភក្ត្រឡើងលើសរសើរតម្កើងព្រះជាម្ចាស់ ហើយកាច់ប្រទានអោយសិស្ស ដើម្បីអោយគេចែកបណ្ដាជនបរិភោគ។

ថ្ងៃមួយ ព្រះយេស៊ូកំពុងផ្កាយដំណើងល្អនៅត្រើយម្ខាងនៃសមុទ្រកាលីឡេ។
មានបណ្ដាជនច្រើនកុះករមកតាមព្រះអង្គ ព្រោះគេបានឃើញទីសម្គាល់ដែលព្រះអង្គបានធ្វើ។
ព្រះយេស៊ូបានយាងកាត់ក្នុងចំណោមហ្វូងមនុស្សបណ្ដើរ ហើយព្យាបាលអ្នកជំងឺ និងបង្រៀនអំពីនគរស្ថានសួគ៌បណ្ដើរ។ ពេលនោះ ថ្ងៃកាន់តែជ្រេ ពួកសាវកនាំគ្នាចូលមកជិតព្រះអង្គ រួចនិយាយថា៖
«ទីនេះស្ងាត់ណាស់ មេឃក៏ងងឹតហើយដែរ បើប្រាប់ឱ្យបណ្ដាជនត្រឡប់ទៅវិញ រកទិញម្ហូបអាហារនៅតាមភូមិ ល្អឬទេ?»
ពេលនោះ ព្រះយេស៊ូមានបន្ទូលថា៖ «មិនបាច់ឱ្យគេត្រឡប់ទៅវិញទេ ចូរអ្នករាល់គ្នាយកម្ហូបអាហារឱ្យគេបរិភោគទៅ »។
ពួកសិស្សទូលថា៖ «ព្រះអង្គអើយ ពួកយើងមិនមានប្រាក់ទេ ហើយទោះបីជាយើងមានប្រាក់ក៏ដោយ ក៏នៅទីនេះមិនអាចទិញអាហារបានឡើយ។ ប៉ុន្តែ យើងអាចឱ្យអាហារទៅមនុស្សទាំងអស់នេះដោយរបៀបណា?»
ព្រះយេស៊ូបានមានព្រះបន្ទូលទៅសាវកថា៖ «ទៅមើលមើល៍ ក្នុងចំណោមបណ្ដាជន មានអ្នកណាយកអ្វីមកខ្លះ?»
ពួកសិស្សបានរកឃើញថាមានក្មេងប្រុសម្នាក់មាននំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយ។
ហើយពួកគេបាននាំយកនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយនោះ ទៅឱ្យព្រះយេស៊ូ។ ព្រះយេស៊ូបានឱ្យបណ្ដាជនអង្គុយជាផ្ទួ ក្នុងមួយផ្ទួហាសិបនាក់។ ពេលរាប់ចំនួនទៅ ឃើញមានប្រុសៗចំនួនរហូតទៅដល់ប្រាំពាន់នាក់។



ព្រះយេស៊ូបានលើកនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយឡើង អធិស្ឋានអរព្រះគុណ រួចមានព្រះបន្ទូលថា៖ «ឥឡូវនេះ សូមចែកឱ្យទៅបណ្ដាជន»។
ពេលនោះ ស្រាប់តែមានរឿងដ៏អស្ចារ្យកើតឡើង! ទោះបីជាចែកនំបុ័ង និងត្រីដល់បណ្ដាជនយ៉ាងណា ក៏មិនចេះអស់ដែរ! ទីបំផុតមនុស្សលើសជាងប្រាំពាន់នាក់ បានបរិភោគឆ្អែតគ្រប់គ្នា។
បណ្ដាជនបានឃើញអំណាចរបស់ព្រះយេស៊ូ ហើយភ្ញាក់ផ្អើល។ ព្រះយេស៊ូក៏មានព្រះបន្ទូលទៅកាន់សាវកម្ដងទៀតថា៖
«ចូរប្រមូលនំបុ័ងដែលនៅសល់ កុំឱ្យមានបាត់មួយដុំសោះឡើយ»។
ពួកសិស្សនាំគ្នារើសសំណល់នំបុ័ងទាំងប្រាំដុំ ដែលបណ្ដាជនបរិភោគសល់ ប្រមូលដាក់បានពេញដប់ពីរល្អី ការនេះបានធ្វើឱ្យពួកសាវក និងបណ្ដាជនដែលដើរតាមព្រះយេស៊ូ កាន់តែជឿ និងគោរពតាមព្រះអង្គថែមទៀត។



• សូមសរសេរតាមខគម្ពីរខាងក្រោម រួចទន្ទេញ។ (លូកា៩៖១៦)

# ព្រះយេស៊ូយកនំប៉័ងទាំងប្រាំដុំ និងត្រីពីរកន្ទុយនោះមកកាន់ ទ្រង់ងើបព្រះភក្ត្រឡើងលើសរសើរតម្កើងព្រះជាម្ចាស់

**សកម្មភាពទី១** សូមគូររូបនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយ។



**សកម្មភាពទី២** សូមគិតពីខ្លឹមសារមេរៀនដែលបានរៀននៅថ្ងៃនេះ រួចផាត់ពណ៌រូបភាពខាងក្រោម។

